# សុន្ទរកថាបើក

## វេទិកាអន្តរសាសនាថ្នាក់ជាតិ នៅកម្ពុជា
## «សូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ»
## ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប

សូមក្រាបថ្វាយបង្គំ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី នន្ទ ង៉ែត ព្រះមហាសង្ឃរាជ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរព សក្ការៈ

សូមក្រាបថ្វាយបង្គំ **សម្តេចព្រះមហាសុមេធាធិបតី នន់ ង៉ែត សម្តេចព្រះសង្ឃនាយក**នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈ

សូមក្រាបថ្វាយបង្គំ **សម្តេចព្រះពោធិវាំង សម្តេចព្រះសង្ឃនាយករងទី២ សម្តេចព្រះវនរ័តន៍ សម្តេចព្រះសង្ឃនាយករងទី៣** និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ

**ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ** មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់

អស់លោកជា**គណៈដឹកនាំជាន់ខ្ពស់នៃឥស្លាមសាសនា បរិស័ទកាតូលិក គ្រិស្ទបរិស័ទដំណឹងល្អ** ព្រមទាំងតាជី យាយជី អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងក្មួយៗយុវជន នារី ជាទីស្រឡាញ់រាប់អាន

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ មានសេចក្តីរំភើបរីករាយ ឥតឧបមា និងសូមសម្តែងនូវការគោរពចំពោះព្រះវត្តមានសម្តេចព្រះមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសុមេធាធិបតី សម្តេចព្រះពោធិវាំង សម្តេចព្រះវនរ័តន៍ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងវត្តមានគណៈដឹកនាំជាន់ខ្ពស់នៃឥស្លាមសាសនា សាសនាកាតូលិក គ្រិស្ទបរិស័ទដំណឹងល្អ ព្រមទាំងឯកឧត្តម លោកជំទាវ តាជី យាយជី អង្គការដៃគូជាតិ និងអន្តរជាតិ យុវជន យុវនារីទាំងអស់ ដែលបានមកជួបជុំគ្នាយ៉ាងច្រើនកុះករ ប្រារព្ធពិធី សូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប នាពេលនេះ ។ នេះគឺជាទិវាដ៏មហោឡារឹក ដែលសាសនាធំៗទាំងបួន ក្នុងព្រះរាជាណាចក្រកម្ពុជា បានឯកភាពគ្នា រៀបចំជាវេទិកាអន្តរសាសនារួមជាមួយ**គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** នៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ប្រមុខដឹកនាំនៃព្រះពុទ្ធសាសនា សាសនាកាតូលិក គ្រិស្ទបរិស័ទដំណឹងល្អ និងគណៈដឹកនាំជាន់ខ្ពស់សាសនាឥស្លាម ក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ យុវជន យុវនារី ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាអំពើឃោរឃៅ និងជាអំពើបាបដ៏

ធ្ងន់ធ្ងរ ដែលជនល្មើសបានប្រព្រឹត្តទៅលើជនរងគ្រោះជាមនុស្ស គ្រប់វ័យ តាំងពីទារក កុមារ យុវ័យ មនុស្សពេញវ័យ មនុស្សចាស់ គ្រប់ភេទ ឥតរើសមុខ ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ បាត់បង់សិទ្ធិជាមនុស្ស បាត់បង់សេចក្តីសុខក្នុងគ្រួសារ ខូចខាតសុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ រហូតដល់អាយុជីវិត របស់មនុស្ស រៀងរាល់ថ្ងៃ រាប់លាននាក់នៅលើពិភពលោក។

យើងទាំងអស់គ្នា ប្តេជ្ញាចិត្ត ធ្វើសកម្មភាពរួមគ្នា និងបន្តផ្សព្វផ្សាយ តាមរយៈការអប់រំសាសនា ដល់សាសនិកគ្រប់និកាយសាសនាទាំងអស់ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បី ឲ្យយល់ដឹង អំពីអំពើជួញដូរមនុស្ស និងនាំគ្នាលុបបំបាត់ទាសភាពសម័យទំនើបនេះ ឲ្យអស់ពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

នេះជាសកម្មភាពដ៏កម្រមួយ ដែលបង្ហាញអំពីភាពសុខដុមរមនានៃសាសនា នៅក្នុងព្រះជាណាចក្រកម្ពុជា ដែលមានគោលដៅរួមគ្នា គឺ ការបង្កើតឲ្យមានសេចក្តីសុខ ផ្លូវកាយ ផ្លូវចិត្តដល់មនុស្សផងគ្នា មិនបៀតបៀនគ្នា មិនប្រឈមមុខដាក់គ្នា ព្រមទាំងបានរួបរួមគ្នា អប់រំចិត្ត អប់រំកាយតាមបែបសាសនារៀងៗខ្លួន ដល់សាសនិក ទាំងឡាយ ឲ្យលើកកម្ពស់សីលធម៌ក្នុងការរស់នៅ និងជួយដាស់តឿនក្រើនរំលឹកគ្នាមិនឲ្យធ្វើនូវអំពើបាបដោយការកេងប្រវ័ញ្ច រំលោភបំពាន ដែលនាំឲ្យមនុស្សដទៃ និងខ្លួនឯងរងទុក្ខវេទនា ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមសម្តែងនូវការគោរព សរសើរអស់ពីដួងចិត្ត និងសូមគាំទ្រសកម្មភាពនេះ ឲ្យមានជារៀងរហូត ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាគ្រឹះដ៏រឹងមាំនៃសីលធម៌ក្នុងការរស់នៅ សេចក្តីសុខ សន្តិភាពផ្លូវកាយ ផ្លូវចិត្តរបស់មនុស្សក្នុងសង្គម ក៏ដូចជាក្នុងប្រទេសជាតិ ដែលជាសេចក្តីត្រូវការចាំបាច់ មិនអាចខ្វះបាន ។

សាសនាគឺជាឱសថ ដែលព្យាបាលជម្ងឺផ្លូវចិត្ត ជាមាគ៌ាតម្រង់ផ្លូវឲ្យមនុស្សដើរទៅតាមផ្លូវសុចរឹត ជាច្បាប់កម្រឹតឲ្យមនុស្សជៀសវាងនូវកំហុសក្នុងការកសាងបាបកម្ម និងឧក្រឹដ្ឋកម្មនានា ឲ្យមនុស្សចេះរស់នៅក្នុងសេចក្តីថ្លថ្នូរ ចេះគោរពខ្លួនឯង និងគោរពគ្នាទៅវិញទៅមក ដែលនេះគឺជាប្រភពនៃសេចក្តីសុខ។

ខ្ញុំព្រះករុណាខ្ញុំ មានជំនឿយ៉ាងមុតមាំថា តាមរយៈវេទិកាអន្តរសាសនាថ្នាក់ជាតិ នៅកម្ពុជា ដែលបាន និងកំពុងរៀបចំពិធីសូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើបនាពេលនេះ នឹងក្លាយទៅជាកម្លាំងសាមគ្គីភាពដ៏រឹងមាំក្នុងសង្គមជាតិកម្ពុជា និងជាស

កម្មភាពដ៏រស់រវើកដែលនឹងធ្វើឲ្យជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋគ្រប់ច្រកល្ហក ឲ្យរួមគ្នាបង្ការទប់ស្កាត់ និងការពារគ្នាទៅវិញទៅមក ពីអំពើជួញដូរមនុស្ស ដោយមិនប្រកាន់និន្នាការ និងជំនឿសាសនាណាមួយឡើយ ដើម្បីឈានទៅបញ្ចប់ទាសភាពសម័យទំនើបដ៏ឃោរឃៅនេះ ។

ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងនូវអំណរព្រះគុណ និងអំណរគុណ ព្រមជាមួយនឹងការកោតសរសើរ ដោយស្មោះ ចំពោះគំនិតផ្តួចផ្តើមរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អង្គការការីតាសកម្ពុជា និងប្រមុខដឹកនាំសាសនាទាំងបួន ក្នុងការរៀបចំឲ្យមានវេទិកាអន្តរសាសនានេះឡើង និងសូមថ្លែងអំណរគុណចំពោះស្មារតីចូលរួមគាំទ្រទាំងធនធានថវិកា កម្លាំងកាយចិត្ត របស់ក្រសួង ស្ថាប័ន និងអង្គការដៃគូទាំងអស់ រហូតដល់មានការប្រារព្ធពិធីសូត្រធម៌ អធិដ្ឋាន បញ្ជូនសារនេះឡើងជាលើកទី១ នៅកម្ពុជា ។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំព្រះរុណាខ្ញុំ សូមឧទ្ទិសបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យ បារមី វត្ថុសក្តិសិទ្ធិ ក្នុងលោក ព្រះអាឡា ព្រះយេស៊ូគ្រិស្ទ ដែលតែងតែជួយទ្រទ្រង់ ថែរក្សាមនុស្សលោក សូមទទួលយកនូវការអធិដ្ឋានរបស់បរិស័ទនៃសាសនាទាំអស់ ដែលមានឆន្ទៈប្រឆាំងដាច់ខាតអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់រូបភាពលើមនុស្ស និងសូមបញ្ចប់ឲ្យបាន នូវទាសភាពសម័យទំនើបនេះ ដើម្បីសេចក្តីសុខរបស់ប្រជាជនកម្ពុជា និងមនុស្សជាតិទាំងឡាយតរៀងទៅ ៕

សូមអរព្រះគុណ សូមអរគុណ